ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការប្រែក្លាយមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

# ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៨។

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល សរសេរកាត់ថា **ម.ជ.ព.ស** ដែលមានឈ្មោះដើមហៅថាមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ ត្រូវបានសម្រេចឱ្យប្រែក្លាយទៅជាគ្រឹះស្ថានសាធារណរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសុខាភិបាល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២.–**

**ម.ជ.ព.ស** ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ជ.ព.ស** មានអាស័យដ្ឋានលេខ ៣៦ មហាវិថី ហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាស័យដ្ឋាននៅពេលអនាគត ជាសមត្ថកិច្ចរបស់ **ម.ជ.ព.ស**។

**មាត្រា ៣.–**

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះមានអត្ថន័យដូចខាងក្រោម :

- **ឱសថ** សំដៅដល់ឱសថសម័យ ឱសថបុរាណ វត្ថុធាតុដើមឱសថ ជាដើម។
- **សម្ភារៈបរិក្ខារពេទ្យ** សំដៅដល់ សំឡី ស្បៃ ទ្រូសស្បែរ៉ូម សឺរ៉ាំង ចេស កាតេទែរ ស្រោមអនាម័យ ជាដើម។
- **ជាតិគីមី** សំដៅដល់ ប្រតិករសារធាតុរួមផ្សំសម្រាប់ផលិតឱសថ ជាដើម.......។
- **សម្ភារៈវេចខ្ចប់** សំដៅដល់ ដប អំពូល ថង់ គម្រប បន្ទះ ជាដើម.....។
- **ម្ហូបអាហារ ឬចំណីអាហារ** សំដៅដល់សារធាតុទាំងអស់ ទោះត្រូវបានកែច្នៃទាំងស្រុង ត្រូវបានកែច្នៃពាក់កណ្តាលសម្រេច ឬមិនទាន់កែច្នៃក្តី ដែលមានទិសដៅសម្រាប់ជាអាហាររបស់មនុស្ស ដោយរាប់បញ្ចូលទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុទាំងអស់ ដែលត្រូវបានប្រើប្រាស់ក្នុងការផលិត ការរៀបចំផលិត និងការកែច្នៃ “ម្ហូបអាហារ”។

**មាត្រា ៤.–**

**ម.ជ.ព.ស** មានភារកិច្ចជាអាទិ៍ ដូចតទៅ :

- សិក្សាស្រាវជ្រាវវាយតម្លៃគុណភាព សុវត្ថិភាព រកសារធាតុដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ហើយនិងជាតិពុលនៅក្នុងផលិតផលឱសថ ជាតិគីមី សម្ភារៈវេចខ្ចប់ឱសថ សម្ភារៈបរិក្ខារពេទ្យ គ្រឿងសម្អាង ផលិតផលជំនួយសុខភាព នៅពេលស្នើសុំចុះទិដ្ឋាការ បញ្ជីកា និងកំពុងធ្វើចរាចរលើទីផ្សារ។
- ពិនិត្យ និងវិភាគគុណភាពម្ហូបអាហារ តាមសំណើរបស់ភាគីពាក់ព័ន្ធ
- វិភាគរកសារធាតុពុល សារធាតុបន្ថែម ហាមឃាត់ រកភាពស្អាតពុំមានមីក្រូសរីរាង្គ បង្កជម្ងឺក្នុងម្ហូបអាហារ និងនៅពេលមានបញ្ហាពុលកើតឡើង

- ចូលរួមសហការ ជាមួយអង្គភាពពាក់ព័ន្ធរបស់ក្រសួងសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចតាមការចាំបាច់ ដើម្បីចុះត្រួតពិនិត្យ និងស្រង់ផលិតផលសំណាកឱសថ គ្រឿងសម្អាង ម្ហូបអាហារ និងវត្ថុធាតុផ្សេងៗដែលប៉ះពាល់ដល់សុខភាពប្រជាជនដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់
- ចូលរួមរៀបចំបង្កើតក្បួនតម្រាឱសថជាតិ និងរៀបចំបទដ្ឋានគុណភាពផលិតឱសថ សម្ភារៈបរិក្ខារពេទ្យ សម្ភារៈវេចខ្ចប់ គ្រឿងសម្អាង និងម្ហូបអាហារ
- បណ្តុះបណ្តាលមុខជំនាញពិនិត្យគុណភាព ដោយសហការជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ
- រៀបចំផែនការអភិវឌ្ឍរបស់ **ម.ជ.ព.ស**
- ជាសេនាធិការឱ្យក្រសួងសុខាភិបាល ក្នុងការតាមដានគុណភាពផលិតផលឱសថ សម្ភារៈបរិក្ខារពេទ្យ សម្ភារៈវេចខ្ចប់ គ្រឿងសម្អាង និងម្ហូបអាហារ
- គ្រប់គ្រងមន្ត្រីរាជការ និយោជិក កម្មករ និងទ្រព្យសម្បត្តិរបស់ **ម.ជ.ព.ស**។

## ជំពូកទី ២
## រដ្ឋបាល និងការគ្រប់គ្រង

### ផ្នែកទី ១
### ក្រុមប្រឹក្សាភិបាល

**មាត្រា ៥.-**

**ម.ជ.ព.ស** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.ស**។

**មាត្រា ៦.-**

**៦.១-** ក្រុមប្រឹក្សាភិបាលមានសមាជិក ១០ (ដប់) រូប ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - តំណាងក្រសួងសុខាភិបាល | ប្រធាន |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - ឥស្សរជនមានចំណេះដឹង និងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល ការងារមន្ទីរពិសោធន៍ជាតិ និងអន្តរជាតិ | សមាជិក |
| - នាយកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ |
| - តំណាងបុគ្គលិកនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ |

**៦.២-** តំណាងបុគ្គលិក នៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ម.ជ.ព.ស** សម្រាប់អាណត្តិនីមួយៗ។

**៦.៣-** ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ០៣ (បី) ឆ្នាំ និងអាចបន្តបានទៀតតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ ។

**មាត្រា ៧.–**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសុខាភិបាល សេដ្ឋកិច្ច ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិម ឬឧក្រិដ្ឋពីតុលាការឡើយ ។

**មាត្រា ៨.–**

**៨.១-** ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**៨.២-**ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យសុខាភិបាល ត្រួតពិនិត្យគុណភាព និងតំណាងដៃគូអភិវឌ្ឍ ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន ។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់យោបល់ តែពុំមានសិទ្ធិបោះឆ្នោតឡើយ ។

**មាត្រា ៩.–**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិស និងធ្វើការត្រួតពិនិត្យនូវដំណើរការរបស់ **ម.ជ.ព.ស** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

- ពិនិត្យ និងសម្រេចលើគម្រោងផែនការអភិវឌ្ឍន៍នៃ **ម.ជ.ព.ស** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចនូវគម្រោងផែនការសកម្មភាពនៃ **ម.ជ.ព.ស**
- ពិនិត្យ និងសម្រេចនូវចំណូល និងចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ព.ស**
- ពិនិត្យ និងសម្រេចនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកភារកិច្ចជាទូទៅ ដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ជ.ព.ស**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរស័ក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ជ.ព.ស** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចនូវក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ម.ជ.ព.ស**
- សម្រេចនូវកិច្ចសន្យា ស្តីពីលទ្ធកម្មសាធារណៈ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ
- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ម.ជ.ព.ស**
- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបានតាមគោលដៅកំណត់ដោយ **ម.ជ.ព.ស** ហើយកំណត់នូវវិធានការកែតម្រូវ ដើម្បីអនុវត្ត ។

**មាត្រា ១០.–**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវសម្រេច ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១១.–**

**១១.១.** ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ព.ស** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំរបស់នាយកនៃ **ម.ជ.ព.ស**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ) រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែគ្មានសិទ្ធិបោះឆ្នោតទេ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

**១១.២.** ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកចំនួនលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើ សំលេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព។

**១១.៣.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ **ម.ជ.ព.ស** នឹងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

**១១.៤. ម.ជ.ព.ស** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ៖

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**១១.៥.** ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី ២

## អង្គការប្រគបគ្គរបស់មជ្ឈមណ្ឌល

**មាត្រា ១២.–**

**ម.ជ.ព.ស** ត្រូវគ្រប់គ្រងដោយនាយកមជ្ឈមណ្ឌល ០១ (មួយ) រូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនេះមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា ១៣.–**

**១៣.១.** នាយកនៃ **ម.ជ.ព.ស** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

នាយកនៃ **ម.ជ.ព.ស** មានភារកិច្ច ៖

- រៀបចំការងារ អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោល-នយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ជ.ព.ស** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ជ.ព.ស** ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សា-ភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រមចំពោះបុគ្គលិកទាំងអស់របស់ **ម.ជ.ព.ស** ដែលកំណត់ដោយក្រុមប្រឹក្សា-ភិបាលស្តីពីការបែងចែកសិទ្ធិអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀតស្តីពីបញ្ហានេះ ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**១៣.២.** នាយកនៃ **ម.ជ.ព.ស** ជាតំណាងរបស់មជ្ឈមណ្ឌលក្នុងការទាក់ទងជាមួយអតិថិជន ។

**១៣.៣.** នាយកនៃ **ម.ជ.ព.ស** ត្រូវស្នើទៅក្រសួងសុខាភិបាល សុំតាក់តែងនាយករងមជ្ឈមណ្ឌលមួយ ឬច្រើនរូបដែលជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។

## ផ្នែកទី ៣
## បុគ្គលិករបស់ ម.ជ.ព.ស

**មាត្រា ១៤.–**

**១៤.១.** បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ជ.ព.ស** រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងសុខាភិបាល ឬមកពីក្រសួងស្ថាប័នដទៃទៀត ។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

**១៤.២.** មជ្ឈមណ្ឌលអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងពលករអណ្តែត ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ ។

**១៤.៣.** បុគ្គលិក **ម.ជ.ព.ស** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់ម.ជ.ព.ស

**មាត្រា ១៥.-**

**១៥.១. ម.ជ.ព.ស** ទទួលដើមទុនដំបូងពីរដ្ឋនូវដីធ្លី និងអចលនវត្ថុ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភ័ណ្ឌចុងក្រោយ ដែលផ្ទៃដីមានប្រមាណជា ៨៧២.២០ ម២ ស្ថិតនៅកែងផ្លូវកម្ពុជាក្រោម និងផ្លូវលេខ ១៣៩ សង្កាត់ មិត្តភាព ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

**១៥.២. ម.ជ.ព.ស** អាចទិញ ប្តូរ លក់ ចលនទ្រព្យ ។ **ម.ជ.ព.ស** អាចទិញ ប្តូរ លក់ អចលនទ្រព្យ ចាំបាច់សម្រាប់ដំណើរការរបស់មជ្ឈមណ្ឌល ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន ។

## ផ្នែកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ម.ជ.ព.ស

**មាត្រា ១៦.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ **ម.ជ.ព.ស** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៧.-**

**១៧.១.** នាយកនៃ **ម.ជ.ព.ស** ជាអណាប័កដើមខ្សែរបស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ត្រូវមានភារកិច្ច :

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

**១៧.២.** អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៨.-**

**១៨.១.** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.ស** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក **ម.ជ.ព.ស** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសម្លេងឆ្នោតឡើយ ។

**១៨.២.** ភ្នាក់ងារគណនេយ្យមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ម.ជ.ព.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ.

**១៨.៣.** ភ្នាក់ងារគណនេយ្យអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន។

**មាត្រា ១៩.–**

**១៩.១.** ប្រភពធនធានរបស់ **ម.ជ.ព.ស** រួមមាន ៖

– ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ជ.ព.ស** នៅពេលផ្តើមបង្កើតដំបូង

– ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ

– អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ជ.ព.ស** បានទទួល

– ប្រាក់ខ្ចីបុលដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ម.ជ.ព.ស**

– ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗដោយ **ម.ជ.ព.ស**

– កម្រៃនៃទ្រព្យសម្បត្តិរបស់ **ម.ជ.ព.ស** និងចំណូលនៃការលក់ទ្រព្យសម្បត្តិដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល

– កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ម.ជ.ព.ស** ។

**១៩.២.** ចំណូលចំណាយជាប្រចាំ ព្រមទាំងមូលធនរបស់ **ម.ជ.ព.ស** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ជ.ព.ស** ត្រូវកំណត់អំពីបែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១៩.៣.** ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ម.ជ.ព.ស** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ។

**មាត្រា ២០.–**

**២០.១.** ការងារគណនេយ្យរបស់ **ម.ជ.ព.ស** រួមមាន ៖

– គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន

– គណនេយ្យអសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ

– គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់ **ម.ជ.ព.ស** ត្រូវ ៖

– ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– គោរពតាមប្លង់គណនេយ្យរបស់ **ម.ជ.ព.ស** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះ ត្រូវបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២០.២.** របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ជ.ព.ស** ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ និងអាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា ២១.-**

មូលនិធិរបស់ **ម.ជ.ព.ស** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយ នៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃ ម.ជ.ព.ស

**មាត្រា ២២.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ **ម.ជ.ព.ស** ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ។

## ផ្នែកទី ៧

## លទ្ធកម្មរបស់ ម.ជ.ព.ស

**មាត្រា ២៣.-**

ការសម្រេចការអនុវត្ត និងការត្រួតពិនិត្យនូវលទ្ធកម្មរបស់ **ម.ជ.ព.ស** ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ជាទាំងឡាយជាធរមានពាក់ព័ន្ធនឹងបទបញ្ជានេះ។

# ជំពូកទី ៣

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៤.-**

**២៤.១.** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ព.ស** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបានបញ្ជូនដោយ **ម.ជ.ព.ស** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៤.២.** លិខិតយល់ព្រមត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង ហើយត្រូវផ្ញើជូនទៅនាយកនៃ **ម.ជ.ព.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយកនៃ **ម.ជ.ព.ស** ត្រូវបញ្ជូនព័ត៌មាននេះ ទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាល មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថា បានទទួលការឯកភាព។ ប្រសិនបើ រដ្ឋមន្ត្រីក្រសួងសុខាភិបាលធ្វើការជំទាស់នូវកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។ កម្មវិធីអភិវឌ្ឍនៃ **ម.ជ.ព.ស** និងថវិកា ចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស។

**មាត្រា ២៥.-**

**២៥.១.** រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចមានយោបល់ជំទាស់លើឯកសារ ដែលបានត្រូវបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ២៤ នៃអនុក្រឹត្យនេះ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់ជូនយោបល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់លើកឡើងនូវការជំទាស់ទាំងនេះ។

**២៥.២.** នាយកនៃ **ម.ជ.ព.ស** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតនូវការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាការបាននូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាមស្តីពីបញ្ហានេះជាលាយល័ក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ២៦.-**

**២៦.១.** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ជ.ព.ស** ក្នុងករណីដែលសេចក្តីសម្រេចនោះ៖

- ផ្ទុយនឹងគោលដៅរបស់មជ្ឈមណ្ឌល
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ។

**២៦.២.** ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់នាយកនៃ **ម.ជ.ព.ស** ហើយនាយកមជ្ឈមណ្ឌលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ២៧.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់មជ្ឈមណ្ឌល ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានចែងជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៨.-**

**២៨.១.** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ជ.ព.ស** ត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយ នាយកនៃ **ម.ជ.ព.ស** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៨.២.** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយកនៃ **ម.ជ.ព.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ នាយកនៃ **ម.ជ.ព.ស** ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៩.-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះ របស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ជ.ព.ស** ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ៖

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងគណនេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញមួយរូបប្រចាំ **ម.ជ.ព.ស** ។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ **ម.ជ.ព.ស** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល ។

**មាត្រា ៣១.-**

**៣១.១.** ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ **ម.ជ.ព.ស** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**៣១.២.** ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**៣១.៣.** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី ៤
## អវសានប្បញ្ញត្ត

**មាត្រា ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ